# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ចម្លើយតបទៅនឹងសំណួររបស់លោក សុខារី
## នៅឡុងប៊ីចសហរដ្ឋអាមេរិក អំពីបញ្ហាអក្សរសាស្ត្រខ្មែរ ។

www.hoksavann.org

ថ្ងៃទី២២ កញ្ញា ២០១១



អក្សរសាស្ត្រខ្មែរប្រែប្រួលខ្លះទៅតាមនយោបាយរបស់ប្រទេស ។ យ៉ាងណាមិញសម័យមុនខ្មែរក្រហមត្រួតត្រាលើប្រទេសកម្ពុជា អក្សរសាស្ត្រខ្មែរមានមូលដ្ឋានប្រកបដោយឯកភាពក្នុងការសរសេរនិងការនិយាយ ព្រោះមានវចនានុក្រមខ្មែរពីរក្បាល ដែលរៀបរៀងនិងសរសេរដោយគណៈកម្មាធិការមួយក្រុម ដែលមានសម្តេចព្រះសុមេធាធិបតីជោតញ្ញាណោជួន-ណាត ព្រះសង្ឃរាជគណៈមហានិកាយជាប្រធាន ។ ជាពិសេសសម័យនោះ បើមានចម្ងល់ខាងអក្សរសាស្ត្រ តែងតែសាកសួរសម្តេច ដោយមាននាទីអក្សរសាស្ត្រផ្សាយតាមវិទ្យុជាតិរៀងរាល់ថ្ងៃសុក្រផង ។ លុះមកដល់សម័យខ្មែរក្រហម ពុំបានធ្វើឲ្យអក្សរសាស្ត្រលូតលាស់ឡើយ ព្រោះរបបនេះគេគិតតែពីនយោបាយមនោគមវិជ្ជាកុម្មុយនិស្ត ។ ខ្មែរក្រហមត្រូវរលត់នៅឆ្នាំ១៩៧៩ ខ្មែរមានភាពទន់ខ្សោយគ្រប់វិស័យ ជាពិសេសវិស័យអក្សរសាស្ត្រជាតិ ។ តាមយើងដឹង សម័យនេះរដ្ឋកម្ពុជាបានប្រមែប្រមូលអ្នកចេះដឹងខាងអក្សរសាស្ត្រ ដែលនៅសេសសល់ពីសម័យខ្មែរក្រហមសម្លាប់ បង្កើតជាគណៈកម្មាធិការរៀបចំអក្សរសាស្ត្រឡើងវិញ ។ ការរៀបចំនេះបានស្តារឡើងវិញបានខ្លះ ប៉ុន្តែគួរឲ្យស្តាយអ្នកដែលរៀបចំនោះពុំបានយកតាមវចនានុក្រមខ្មែរទាំងស្រុងឡើយ មានតែកែអក្សរសរសេរខ្លះ ។ ដូចពីដើមធ្លាប់សរសេរជាអក្សរ «ណា» «ឡ» ជាដើម ទៅជាសរសេរជាអក្សរ «ន» និង «ល» ទៅវិញ ។ សំណេរបែបនេះ គឺធ្វើតាមទស្សនៈរបស់លោកកេង-វ៉ាន់សាក់ ដែលផ្ទុយពីការសរសេរតាមវចនានុក្រមរបស់សម្តេចជួន-ណាត ។ ពេលនេះ យើងមានចិត្តរីករាយនិងសង្ឃឹមឡើងវិញ ដោយរាជរដ្ឋាភិបាលខ្មែរបច្ចុប្បន្ននេះ បានបង្កើតក្រុមប្រឹក្សាជាតិខាងអក្សរសាស្ត្រ ដើម្បីរៀបចំអក្សរសាស្ត្រជាតិ ឲ្យមានឯកភាពខាងការនិយាយនិងការសរសេរ ដោយយកវចនានុក្រមរបស់សម្តេចជួន-ណាតជាមូលដ្ឋាន ។

តទៅនេះ យើងសូមឆ្លើយទៅនឹងសំណួររបស់លោក សុខារី ៖

★ ភាសាជាតិយើងមានតែមួយទេ ដែលខ្មែរនៅគ្រប់កន្លែងគ្រប់ខេត្តនិយាយស្តាប់គ្នាបាន វៀរលែងតែជនជាតិភាគតិចនៅខេត្តខ្លះ ដូចជាខេត្តរតនគិរី មណ្ឌលគិរីនិយាយភាសាជនជាតិភាគតិច ប៉ុន្តែឥឡូវនេះបាននិយាយភាសាខ្មែរបានច្រើនហើយតាមរយៈការបង្កើតសាលារៀននិងទំនាក់ទំនងខាងការលក់ដូរ ។ បានសេចក្តីថា ខ្មែរមានឯកភាពខាងការនិយាយ និងមានឯកភាពខាងការប្រើប្រាស់អក្សរ គឺអក្សរសរសេរមានតែមួយបែប ។ ផ្ទុយទៅវិញ នៅប្រទេសខ្លះដូចជាប្រទេសចិនមានភា-សារាប់រយ ។ ភាសាសំរាយ គឺជាពាក្យខ្មែរសុទ្ធ ដូចជាពាក្យថា ខ្ញុំទៅផ្សារ ខ្ញុំគោរពឪពុកម្តាយជាដើម ។ មានពាក្យខ្មែរខ្លះ ខ្ចីពីបាលី ដូចជាពាក្យថាមាតាបិតា វត្ត ព្រះវិហារ កុដិ សាលា គុណទោសជាដើម ។ ពាក្យខ្មែរខ្លះខ្ចីពីសំស្រ្កឹតដូចជាពាក្យថា ប្រ-យោជន៍ បុណ្យ វិទ្យា បុកពារជាដើម ។ ឯភាសាប្រាក្រិត្យ ជាភាសាមួយនៅប្រទេសឥណ្ឌាសម័យបូរាណ តាមឯកសារមួយថា ព្រះពុទ្ធហាក់ដូចជាប្រើភាសានេះផងក្នុងការសំដែងធម៌ទេសនារបស់ព្រះអង្គ ។ មកដល់ពេលនេះ ភាសានេះហាក់ដូចជាចង់បាត់បង់ទៅហើយ ហើយគេពុំបានឃើញអក្សរពួកនេះសរសេរបែបណាផង ។ ភាសានិងអក្សរខ្មែរមានវេយ្យា-ករណ៍មានប្រយោគប្រធានត្រឹមត្រូវ ដូចជាភាសានិងអក្សរនៃប្រទេសជឿនលឿនដែរ ប៉ុន្តែភាសានិងអក្សរខ្មែរពុំមានវិភត្តិពុំប្តូរពាក្យទៅតាមលិង្គឡើង ដូចជាពាក្យខ្មែរថា «ខ្ញុំទៅរៀន» ប្រយោគនេះទោះបីប្តូរប្រធានពី«ខ្ញុំ» ទៅជា«ឯង» ជា«លោក» ជា«នាង» ជា«ឯកវចនៈ»ក្តី ជា«ពហុវចនៈ»ក្តី ក៏កិរិយាស័ព្ទពុំប្តូរឡើយ គឺពាក្យថា«ទៅ»នៅតែសរសេរ«ទៅ»ដដែល ។ ដោយភាសាខ្មែរមានប្រយោគប្រធានត្រឹមត្រូវនេះហើយ ទើបនិយាយក្តីសរសេរក្តី គេអាចយល់សេចក្តីបាន ។ ពាក្យថា ព្រះ, សីល, សង្ឃ, ធម៌, សិស្ស សុទ្ធតែមានន័យប្រើជានាម ។ ពាក្យថា «ព្រះ» អាចប្រើបានពីរបែប ម្យ៉ាងប្រើជានាមផ្ទាល់តែម្តង គឺព្រះបើពុទ្ធសាសនាសំដៅយកអ្នកត្រាស់ដឹង ប្រើម្យ៉ាងទៀតដាក់នៅមុខនាមដូចពាក្យថាព្រះពុទ្ធ ។ សីល ការរក្សាកាយវាចាប្រ-កបដោយសុចរិត, សង្ឃ ក្រុមឬពួកអ្នកបួស, ធម៌ មានន័យច្រើនយ៉ាង តែក្នុងទីនេះសំដៅយកពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ, សិស្ស អ្នកសិក្សារៀនសូត្រ ។

★ ពាក្យថា «អត្តា» និង «អនត្តា» នេះ គប្បីយល់ដូចតទៅនេះ ៖

មុនព្រះពុទ្ធត្រាស់ដឹង សាសនាព្រាហ្មណ៍ដែលផ្លាស់មកជាសាសនាហិណ្ឌូយល់ថា មនុស្សសត្វដែលស្លាប់ទៅ គឺស្លាប់តែរូបរាងកាយទេ ឯចិត្តវិញ្ញាណពុំស្លាប់ឡើយ ដែលបាលីថា «អត្តា» សំស្ក្រឹតថា «អាត្មន» ខ្មែរថា «ព្រលឹងវិញ្ញាណ» បារាំងថា «âme, esprit» អង់គ្លេសថា «mind, self ego» ជាដើម ចេញទៅរកកំណើតទៀត ប្រៀបដូចផ្ទះត្រូវភ្លើងឆេះ អ្នកម្ចាស់ផ្ទះបានចេញពីផ្ទះដែលឆេះទៅកសាងផ្ទះថ្មីទៀត ។ ទស្សនៈនេះព្រះសម្ពុទ្ធបានបដិសេធ ដោយព្រះអង្គបានបញ្ជាក់ថា ចិត្តវិញ្ញាណដែលកើតឡើងបាន ដោយអាស្រ័យអាយតនៈខាងក្រៅ៦គឺ រូប សម្លេង ក្លិន រស សម្ផស្ស និង ធម្មា (អារម្មណ៍ដែលចិត្តគោង) ទើបកើតចិត្តវិញ្ញាណឡើង កាលណារូបរាងកាយស្លាប់ ត្រូវស្លាប់ទាំងអស់ ទាំងកាយទាំងវិញ្ញាណ ទើបព្រះពុទ្ធប្រើពាក្យថា «អនត្តា» (ន អត្តា) មិនមែនខ្លួន ព្រោះសភាវៈកើតរលត់មិនស្ថាប់បង្គាប់ ។ល។

★ ព្រះពុទ្ធគ្រប់ព្រះអង្គ ជាពិសេស ព្រះពុទ្ធសមណគោតមក្នុងភទ្ទកប្បនេះ តែមានពុទ្ធញ្ញាណពិសេសប្រសើរជាងមនុស្ស

ទេព្តាទាំងឡាយ បើព្រះអង្គក្រាលញាណចង់ដឹងអ្វី អាចដឹងបានភ្លាម គ្មានសភាវៈអ្វីមួយមករារាំងមិនឲ្យព្រះអង្គជ្រាបឡើយ ញាណនេះហៅថា អនាវរញ្ញាណ ឬហៅ សព្វញ្ញុតញ្ញាណ គឺត្រាស់ដឹងសព្វ ស្របតាមបារមីដែលព្រះអង្គកសាងគ្មានរុញរា គ្មានស្មាក់ស្មើរ ទោះបីមានអ្វីរាំងពីមុខក៏ដោយ ។ សូមសរសើរលោក សុខារី ដែលយកចិត្តទុកដាក់ចំពោះអក្សរសាស្ត្រខ្មែរ នេះ ។៚

❑

*(<u>កកន</u> ៖ ខ្ញុំ (លី-ឡៀប) មិនមែនជាភាសាវិទូទេ គ្រាន់តែសូមធ្វើការចាប់អារម្មណ៍ទៅលើការប្រើប្រាស់ពាក្យខ្មែរខ្លះៗប៉ុណ្ណោះ ។ សព្វថ្ងៃនេះ នៅស្រុកខ្មែរគេនិយមចូលចិត្តប្រើពាក្យ «ក៏ដូចជា» ជំនួសពាក្យ «និង» ឬ «ព្រមទាំង» សឹងនៅគ្រប់ទីកន្លែង ខ្ញុំយល់ថា គេគួរវិលត្រឡប់ទៅប្រើពាក្យ «និង» ឬពាក្យ «ព្រមទាំង» វិញល្អជាង ។*

*គេប្រើពាក្យ «ព្រះតេជគុណ» ជំនួសពាក្យ «ព្រះតេជព្រះគុណ» ។ ពាក្យ «ព្រះតេជគុណ» គ្មាននៅក្នុងវចនានុក្រមរបស់សម្តេចសង្ឃជួន-ណាតទេ ។*

*ពាក្យ «គណៈកម្មការ» និងពាក្យ «គណៈកម្មាធិការ» ។ ពាក្យទាំងពីរនេះមានន័យខុសគ្នា ៖ ពាក្យ «គណៈកម្មការ» មានន័យថា ក្រុមមួយដែលគេជ្រើសរើសឡើងដោយពិធីបោះឆ្នោត ។ ឯចំណែកពាក្យ «គណៈកម្មាធិការ» វិញមានន័យថា ក្រុមមួយដែលគេបង្កើតឡើងដោយការចាត់តាំង)* ។

*　　　　*

*